ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍នេសាទ ប្រឡាយមាស

## រយៈពេល ៣ឆ្នាំ (២០១៨ ដល់ ២០២០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ប្រឡាយមាស |
| ភូមិ | ៖ | ប្រឡាយមាស |
| ឃុំ | ៖ | ប្រឡាយមាស |
| ស្រុក | ៖ | កំពង់លែង |
| ខេត្ត | ៖ | កំពង់ឆ្នាំង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ ប្រឡាយមាស

## រយៈពេល ៣ឆ្នាំ (២០១៨ ដល់ ២០២០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ប្រឡាយមាស |
| ភូមិ | ៖ | ប្រឡាយមាស |
| ឃុំ | ៖ | ប្រឡាយមាស |
| ស្រុក | ៖ | កំពង់លែង |
| ខេត្ត | ៖ | កំពង់ឆ្នាំង |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**១.ស្ថានភាពទូទៅ**
**២.អំពីប្រជាសាស្ត្រ**
ក.ប្រជាជន
ខ.មុខរបរ
**៣.កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**
ក.ទីតាំង
ខ.ដែននេសាទ
គ.តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស
**៤.ការធ្វើនេសាទ**
ក.អ្នកនេសាទ
ខ.ឧបករណ៍នេសាទ
គ.ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ
**៥.ផែនការគ្រប់គ្រងសហគមន៍នេសាទ**
ក.ទស្សនៈវិស័យ
ខ.គោលបំណង
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
គ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ
គ២.ផែនការកែលំអដែននេសាទ
គ៣.ផែនការកំណត់និងរៀបចំកន្លែអភិរក្ស
គ៤.ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹក
គ៥.ការផែនការអភិវឌ្ឍន៍វារីវប្បកម្ម
គ៦.ផែនការចុះទប់ស្កាត់បទល្មើសនេសាទ
គ៧.ផែនការបណ្តុះបណ្តាល
គ៨.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍
ឃ.យុទ្ធសាស្ត្រ
-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ឆ្នាំ
-តារាងកម្មវិធីការងារ
-តារាងឧបសម្ព័ន្ធ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទប្រឡាយមាស ត្រូវបានរៀបចំឡើងដោយបហាសន្និបាតកំណើតដំបូងនៅ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ បានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ។

សហគមន៍នេសាទប្រឡាយមាស មានទីតាំងស្ថិតនៅក្នុងភូមិប្រឡាយមាស ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលមានសមាជិកចំនួន៤៣០នាក់ ស្រី២១០នាក់ និងមានគណៈកម្មការចំនួន០៩នាក់ ស្រី ០នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន៨០គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ ខ្លួនរួមមាន៖

- លក្ខន្តិកៈសហគមន៍នេសាទ
- បទបញ្ជាផ្ទៃក្នុង
- បញ្ជីឈ្មោះសមាជិកសហគមន៍
- ចុះកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍
- ប្រមូលពត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ចូលរួមប្រជុំជាមួយភូមិ ឃុំ
- ចូលរួមដាំកូនឈើព្រៃលិចទឹក
- ចូលរួមអប់រំផ្សព្វផ្សាយ
- រៀបចំកន្លែងអភិរក្ស
- សហការជាមួយអាជ្ញាធរមូលដ្ឋាននិងជំនាញជលផល
- ចុះល្បាតក្នុងដែនសហគមន៍នេសាទ។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន១១៧៦នាក់ស្រី៤៤៣នាក់ ក្នុងនោះមានជនជាតិខ្មែរ១១៧នាក់ ខ្មែរឥស្លាមចំនួន០នាក់ អាណិកជនវៀតណាមចំនួន០នាក់។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន ៣៨នាក់
- ចំនួជនពិការក្នុងសហគមន៍នេសាទមានចំនួន ៦នាក់ ស្រី ០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន ៤០នាក់ ស្រី ៣៨នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន ០៥នាក់ ស្រី ០២នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន ១៥នាក់ ស្រី ១១នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់មាន

- អ្នកមិនចេះអក្សរមានចំនួន ១៥នាក់ ស្រី ១០នាក់
- កំរិតថ្នាក់បឋមសិក្សាចំនួន ១៥០នាក់ ស្រី២៥នាក់
- កំរិតមធ្យមសិក្សាចំនួន ៣០នាក់ ស្រី២៥នាក់
- និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ២៤នាក់ ស្រី០៩នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើចំការ សណ្តែក ពោត ល្ង ចំនួន ៣០១នាក់ ស្មើនឹង ១០០គ្រួសារ
- ធ្វើនេសាទចំនួន ២៥៨នាក់ ស្មើនឹង ៨៦គ្រួសារ
- ចំណាកស្រុក(ក្នុងប្រទេស) ៦០នាក់
- កម្មករចំនួន ២០នាក់
- ជំនួយការភូមិចំនួន ០២នាក់
- លក់ដូរចំនួន ១០នាក់
- ជាងផ្ទះចំនួន ១៥នាក់
- ចិញ្ចឹមសត្វ មាន់ ទា ជ្រូក ៥០គ្រួសារ
- គ្រូបង្រៀនចំនួន ០៣គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៧,២០០,០០០រៀល

## ៣.តំបន់នេសាទសហគមន៍និងធនធានជលផលដែលមាននៅតំបន់នេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍ **ប្រឡាយមាស** ត្រូវលុបចេញពីអតីតឡូត៍នេសាទលេខ២ ជាកន្លែងដែលមានដែននេសាទតាម បឹងបួរ ព្រែក អូរ ព្រៃលិចទឹក ដើម្បីចូលរួមគ្រប់គ្រង ថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយចិរភាព។

កន្លែងនេសាទសហគមន៍ **ប្រឡាយមាស** មានទំហំ ៣១៥០ហិចតា និងមានកំណត់និយាមការដូចចែងនៅក្នុងកិច្ចព្រមព្រៀង ។

**មានព្រំប្រទល់ ៖**

- ខាងជើងទល់នឹងភូមិក្រម៉ាល់
- ខាងត្បូងទល់នឹងភូមិកោះឫស្សី និង កាដោក
- ខាងកើតទល់នឹងភូមិអន្លង់កញ្ចះ
- ខាងលិចទល់នឹងភូមិក្រងផ្តិលនិងភូមិក្រម៉ាល់

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍ **ប្រឡាយមាស** មានបឹងចំនួន០៨ ព្រែកចំនួន២ អូរចំនួន៣ ថ្លុកចំនួន២។

- ឈ្មោះបឹងតាព្រហ្ម ទំហំ ៥០មx២០០០ម(១០ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ

- ឈ្មោះបឹងតាព្រះ ទំហំ ៤០មx១៥០០ម(៦ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះបឹងសូសំអុយ ទំហំ ៤០មx២៥០០ម(១០ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះបឹងក្បាលខ្សៀរ ទំហំ ៨០មx៧០០ម ធ្វើនេសាទ(៥,៦ហិកតា) ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះបឹងឃ្លុយ ទំហំ ៥០មx៥០០ម(២,៥ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះបឹងក្រូស ទំហំ ៥០មx៥០០ម(២,៥ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះបឹងដំរីសំរុក ទំហំ ៤០មx១០០០ម(៤ហិកតា) ធ្វើនេសាទ ពីខែមករាដល់ ខែធ្នូ
- ឈ្មោះបឹងចោរ ទំហំ ៣០មx៣០០ម(០,៩ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះព្រែកស្លាបកុក ទំហំ ១០០មx៧០០ម(៧ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះព្រែកស្វាយកាប ទំហំ ៥០មx៣០០០ម(១៥ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះអូរកន្ទោល ទំហំ ១៥មx១០០០ម(១,៥ហិកតា) ធ្វើនេសាទ ពីខែមករា ដល់ ខែធ្នូ
- ឈ្មោះអូរឡាប៉ុកតូច ទំហំ ១៥មx១០០០ម(១,៥ហិកតា) ធ្វើនេសាទពីខែមករា ដល់ ខែធ្នូ
- ឈ្មោះអូរក្បាលខ្សៀរ ទំហំ ៥មx១៥០ម(០,០៧៥ហិកតា) ធ្វើនេសាទពីខែមករា ដល់ ខែធ្នូ
- ឈ្មោះថ្លុកក្រាញ់ ទំហំ ៣០មx៣០ម(០,៩ហិកតា) ធ្វើនេសាទពីខែមករា ដល់ ខែធ្នូ
- ឈ្មោះថ្លុកផ្ទោលបាក់ ទំហំ ៥០មx៣០០ម(១,៥ហិកតា) ធ្វើនេសាទពីខែមករា ដល់ ខែធ្នូ

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- ១ បឹងក្បាលខ្សៀរ ទំហំ ៥,៦ហិកតា

**ឃ.ធនធាជលផល**

- **ប្រភេទត្រី** (ត្រីរ៉ស់ ឆ្តោ ផ្ទក់ ត្រីព្រួល ត្រីប្រា ត្រីក្រាយ ត្រីឆ្លាំង ត្រីកេស ត្រីឆ្ពោក ត្រីក្អែក ត្រីគ្រសក់ ត្រីគល់រាំង ត្រីកញ្ចុះ ត្រីក្រាញ់ ត្រីរៀល ត្រីចង្វា ត្រីឆ្លូញ ត្រីពោធិ៍ ត្រីដំរី ត្រីតាអោន ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ត្រប់ ត្រីលេញ ត្រីខ្លាំងហាយ ត្រីឆ្ពិន ត្រីគ្រំ ត្រីប្រម៉ា ត្រីកន្លង់ ត្រីឆ្ងៀត ត្រីកញ្ជ្រូក ត្រីកាហែ ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីបណ្តូលអំពៅ ត្រីក្បក ត្រីអណ្តាតឆ្កែ ត្រីច្រកែង ត្រីប្រម៉ា ត្រីអង្កត់ប្រាក់............ )
- **ប្រភេទវារីសត្វ** (អណ្តើក ឆ្អារដាវ កង្កែប កន្ធាយ ពស់ អន្ទង់ ក្អែកទឹក ក្រសា ភេ មាន់ទឹក ទោមកុក ក្តាម ខ្ចៅ ខ្យង លៀស គ្រំ។ល។
- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ** ( ដើមកន្សែង ដើមទន្លា កក់ជ្រុក កក់ក្តាម ឈូក ចន្ទល់ភ្នំ ត្រាវអណ្តែត សណ្តាន់ ដើមម្តេញ ដើមត្រឡក ដើមសន្ទែ ដើមខ្ទំ ដើមសង្ឃ្សរ សារាយសាបរាំង ត្រស់ ត្នួរ ព្រលិត ត្រកួន រំចង់ ថ្លើមអណ្តើក បន្លាស្អិត ប្របួយមេ ប្របួយឈ្មោល ភ្នំភ្លើង សណ្តាន់ ដើមរំពាក់ ដើមម្តេញ ដើមដៃខ្លា វល្លិ៍ត្អើក ស្លាបទា កំប្លោក ចកបាយទា កំពីងពួយស កំពីពួយក្រហម កក់ជ្រុង សារាយ កញ្ឆែត ស្មៅថ្នក់ទឹក ចំប្លង។ល។

## ៤. ការធ្វើនេសាទ

### ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍ នេសាទមានចំនួន ៤៣០នាក់ ស្រី២១០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ៥៨នាក់ ស្រី២០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៣០នាក់ ស្រី៦នាក់

### ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងរាយ មងបណ្តែត | ដៃ(១ដៃ=៧៥ម) | ៦០ | ១០ដៃ/គ្រួសារ | ចំនួន=៤៥០០០ម ក្រឡា=0,0២ម-0,0៥ ម | ខែមិថុនា ដល់ ខែធ្នូ |
| សំណាញ់ | វង់ | ១០ | ១វង់/គ្រួសារ | ១០វង់ | ខែមករា ដល់ ខែធ្នូ |
| មងប្រយុង | វង់ (១វង់=៣០ម) កំពស់ ១ម-៣ម ក្រឡា0,0៥-0,0៦ | ៤០ | ១វង់/គ្រួសារ | ៤០វង់ | ខែមិថុនា ដល់ ខែធ្នូ |
| សន្ទូចរនង | ផ្លែ | ៤៨ | ១០០០ផ្លែ/នាក់ | ចំនួន=៤៨០០០ផ្លែ | ខែសីហា ដល់ ខែធ្នូ |
| លបលួង | គ្រឿង | ៣០ | ៦គ្រឿង/នាក់ | ចំនួន=១៨០គ្រឿង កំពស់=១,៥ម មុខកាត់=0,៦ម | ខែមករា ដល់ ខែធ្នូ |
| លបទល់ | គ្រឿង | ២៥ | ៧គ្រឿង/គ្រួសារ | ចំនួន=១៧៥គ្រឿង កំពស់=0,៧ម មុខកាត់=0,៣ម | ខែមករា ដល់ ខែធ្នូ |
| លាន់ | គ្រឿង | ១៥ | ១៥០គ្រឿង/គ្រួសារ | ២២៥០គ្រឿង មុខកាត់=0,0៨ម ប្រវែង=២ម. | ខែកក្កដា ដល់ ខែធ្នូ |
| កន្ទ្រុំត្រីខ្ចឹង | គ្រឿង | ៥ | ៥០គ្រឿង/គ្រួសារ | ២៥០គ្រឿង មុខកាត់=0,២៥ម ប្រវែង=១ម | ខែមេសា ដល់ ខែមិថុនា |
| សៃយឺន កំពីស | គ្រឿង | ៥ | ២៥០គ្រឿង/គ្រួសារ | ១២៥០គ្រឿង មុខកាត់=0,២ម ប្រវែង=0,២ម | ខែកក្កដា ដល់ ខែធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេស |
|---|---|---|---|
| ទូកម៉ាស៊ីន | ១៦០គ្រឿង | ៧០០គក្រ-១៥០០គក្រ | ៦,៥សេស - ២៤សេស |

ឧបករណ៍នេសាទនិងទូករបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងរាយ មងបណ្ដែត | ដៃ(១ដៃ=៧៥ម) | ១៥ | ១០ដៃ/គ្រួសារ | ចំនួន=១១២៥០ម ក្រឡា=0,0២ម-0,0៥ ម | ខែមិថុនា ដល់ ខែធ្នូ |
| សំណាញ់ | វង់ | ២ | ១វង់/គ្រួសារ | ២វង់ | ខែមករា ដល់ ខែធ្នូ |
| មងប្រយុង | វង់ (១វង់=៣០ម) កំពស់ ១ម-៣ម ក្រឡា0,0៥-0,0៦ | ៧ | ១វង់/គ្រួសារ | ៧វង់ | ខែមិថុនា ដល់ ខែធ្នូ |
| សន្ទូចរនង | ផ្លែ | ៩ | ១000ផ្លែ/នាក់ | ចំនួន=៩000ផ្លែ | ខែសីហា ដល់ ខែធ្នូ |
| លបលួង | គ្រឿង | ២ | ៧គ្រឿង/នាក់ | ចំនួន=១៤គ្រឿង កំពស់=១,៥ម មុខកាត់=0,៦ម | ខែមករា ដល់ ខែធ្នូ |
| លបទល់ | គ្រឿង | ៤ | ៨គ្រឿង/គ្រួសារ | ចំនួន=៣២គ្រឿង កំពស់=0,៧ម មុខកាត់=0,៣ម | ខែមករា ដល់ ខែធ្នូ |
| លាន់ | គ្រឿង | ៣ | ២00គ្រឿង/គ្រួសារ | ៦00គ្រឿង មុខកាត់=0,0៨ម ប្រវែង=២ម | ខែកក្កដា ដល់ ខែធ្នូ |
| កន្សំត្រីខ្ចឹង | គ្រឿង | ៨ | ៥0គ្រឿង/គ្រួសារ | ៤00គ្រឿង មុខកាត់=0,២៥ម ប្រវែង=១ម | ខែមេសា ដល់ ខែមិថុនា |
| សៃយឺន កំពឹស | គ្រឿង | ៥ | ៣00គ្រឿង/គ្រួសារ | ១៥000គ្រឿង មុខកាត់=0,២ម ប្រវែង=0,២ម | ខែកក្កដា ដល់ ខែធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេស |
|---|---|---|---|
| ទូកម៉ាស៊ីន | ២0គ្រឿង | ៧00គក្រ-១៥00គក្រ | ៦,៥សេស - ២៤សេស |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាជិកដែលមកពីខាងក្រៅសហគមន៍នេសាទ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងរាយ | ដៃ(១ដៃ=៧៥ម) | ២0 | ១0ដៃ/គ្រួសារ | ចំនួន=៤៥000ម | ខែមិថុនា ដល់ ខែធ្នូ |

| | | | | | |
|---|---|---|---|---|---|
| មងបណ្តែត | | | | ក្រឡា=0,0២ម-0,0៥ ម | |
| សំណាញ់ | វង់ | ២ | ១វង់/គ្រួសារ | ២វង់ | ខែមករា ដល់ ខែធ្នូ |
| មងប្រយុង | វង់ (១វង់=៣០ម) កំពស់ ១ម-៣ម ក្រលា0,0៥-0,0៦ | ១០ | ១វង់/គ្រួសារ | ១០វង់ | ខែមិថុនា ដល់ ខែធ្នូ |
| សន្ទូចរនង | ផ្លែ | ១២ | ១០០០ផ្លែ/នាក់ | ចំនួន=១២០០០ផ្លែ | ខែសីហា ដល់ ខែធ្នូ |
| លបលួង | គ្រឿង | ៣ | ៦គ្រឿង/នាក់ | ចំនួន=១៨គ្រឿង កំពស់=១,៥ម មុខកាត់=0,៦ម | ខែមករា ដល់ ខែធ្នូ |
| លបទល់ | គ្រឿង | ៥ | ៧គ្រឿង/គ្រួសារ | ចំនួន=៣៥គ្រឿង កំពស់=0,៧ម មុខកាត់=0,៣ម | ខែមករា ដល់ ខែធ្នូ |
| លាន់ | គ្រឿង | ៥ | ១៥០គ្រឿង/គ្រួសារ | ៧៥០គ្រឿង មុខកាត់=0,0៨ម ប្រវែង=២ម | ខែកក្កដា ដល់ ខែធ្នូ |
| កន្សៃត្រីខ្ចឹង | គ្រឿង | ៤ | ៥០គ្រឿង/គ្រួសារ | ២០០គ្រឿង មុខកាត់=0,២៥ម ប្រវែង=១ម | ខែមេសា ដល់ ខែមិថុនា |
| សៃយឺនកំពឹស | គ្រឿង | ២ | ៣០០គ្រឿង/គ្រួសារ | ៦០០គ្រឿង មុខកាត់=0,២ម ប្រវែង=0,២ម | ខែកក្កដា ដល់ ខែធ្នូ |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កម្លាំងសេស** |
|---|---|---|---|
| ទូកម៉ាស៊ីន | ៣០គ្រឿង | ៧០០គក្រ-១៥០០គក្រ | ៦,៥សេស - ២៤សេស |

## ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទឧបករណ៍ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|
| | **រដូវប្រាំង** | **រដូវវស្សា** | **សរុបប្រចាំឆ្នាំ** |
| ត្រីគ្រប់ប្រភេទ | ៧៤០គក្រ | ១២០០គក្រ | ១៩៤០គក្រ |
| ក្តាម ខ្យង កំពិស ខ្ចៅ | ៣០០គក្រ | ៣៥០គក្រ | ៦៥០គក្រ |

## ៥.ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទ **ប្រឡាយមាស** មានទស្សនៈវិស័យចូលរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

ចង់ឲ្យសមាជិកសហគមន៍នេសាទមានការចូលរួមបង់បដិភាគ និងមានការចូលរួមបង់វិភាគទាន ពីអ្នកខាងក្រៅក្នុងការរួមចំណែកការពារ និងគ្រប់គ្រងធនធានធម្មជាតិឲ្យមាននិរន្តភាព។

សហគមន៍មានកន្លែងអភិរក្ស សម្រាប់បង្កើតកន្លែងទេសចរណ៍ធម្មជាតិ ដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ធ្វើការអភិវឌ្ឍន៍សហគមន៍ឲ្យមាននិរន្តរភាព ។

ចូលរួមគ្រប់គ្រង និងថែរក្សាការពារធនធានធម្មជាតិ សម្រាប់រក្សាទុកឲ្យប្រជានេសាទ រកជាលក្ខណៈគ្រួសារដោយបែងចែកផលប្រយោជន៍ ធនធានជលផលប្រកបដោយសមធម៌ និងធ្វើឲ្យប្រសើរឡើងនូវជីវភាព។

ចង់ឲ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ និងចូលរួមការពារធនធានធម្មជាតិ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានជលផល។

មានការចូលរួមសហការ និងគាំទ្រពីអាជ្ញាធរ ព្រមទាំងមន្ត្រីជំនាញ ក្នុងការអន្តរាគមន៍បទល្មើសនិងដោះស្រាយបញ្ហាផ្សេងៗនៅក្នុងសហគមន៍។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម៖**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតិឲ្យប្រើ | | |
|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន |
| បឹងតាព្រហ្ម<br>បឹង សួរសំអុយ<br>បឹង តាព្រះ | មករា ដល់ ធ្នូ | មង | ៣០០ម/នាក់<br>ក្រឡា=២,៥-៤,៥ ស ម<br>ជម្រៅ=១,៥ ម | ២៥០នាក់ |
| | មករា ដល់ ធ្នូ | សន្ទូចរនង | ៨០០ផ្លែ/នាក់<br>(លេខ១២,១៣) | ១០០នាក់ |
| | មករា ដល់ ធ្នូ | លបលួង | ១០គ្រឿង/ម្នាក់ | ៤៥នាក់ |
| | មករា ដល់ ធ្នូ | លបទល់ | ១១គ្រឿង/ម្នាក់ | ៥០នាក់ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/ម្នាក់ | ៣០នាក់ |
| | កក្កដា-ធ្នូ | សៃយឺនកំពិស | ២៥០គ្រឿង/ម្នាក់ | ៥នាក់ |
| | មេសា-មិថុនា | កន្ទ្រុំត្រីខ្ញឹង | ៥០គ្រឿង/ម្នាក់ | ១០នាក់ |
| | មីនា-កក្កដា | ថ្នងឬជន | ១វង់/ម្នាក់ | ៦០នាក់ |
| | មីនា-ឧសភា | អួនអូសដៃ | ១វង់/ម្នាក់ | ៤នាក់ |
| | កក្កដា ដល់ ធ្នូ | លាន់ | ១០០គ្រឿង/នាក់ | ៥០នាក់ |
| បឹង ក្បាលខ្សៀរ<br>បឹង ដំរីសំរុក | មករា ដល់ ធ្នូ | មង | ២៥០ម/នាក់<br>ក្រឡា=២,៥-៤,៥ ស ម | ២២០នាក់ |

| | | | | |
|---|---|---|---|---|
| បឹង ឃ្លុយ<br>បឹង ក្រូស<br>បឹងចោរ | | | ជម្រៅ=១,៥ ម | |
| | **មករា ដល់ ធ្នូ** | សន្ទូចរនង | ៨០០ផ្លែ/នាក់<br>(លេខ១២,១៣) | ៨០នាក់ |
| | **មករា ដល់ ធ្នូ** | លបលួង | ៨គ្រឿង/ម្នាក់ | ៤០នាក់ |
| | **មករា ដល់ ធ្នូ** | លបទល់ | ៩គ្រឿង/ម្នាក់ | ៤៥នាក់ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/ម្នាក់ | ៣០នាក់ |
| | កក្កដា-ធ្នូ | សៃយ៉ឺនកំពិស | ២៥០គ្រឿង/ម្នាក់ | ៥នាក់ |
| | មេសា-មិថុនា | កន្សៃត្រីខ្ទឹង | ៤០គ្រឿង/ម្នាក់ | ៨នាក់ |
| | មីនា-កក្កដា | ថ្នងឬជន | ១វង់/ម្នាក់ | ៤០នាក់ |
| | មីនា-ឧសភា | អួនអូសដៃ | ១វង់/ម្នាក់ | ៤នាក់ |
| | កក្កដា ដល់ ធ្នូ | លាន់ | ៨០គ្រឿង/នាក់ | ៣៥នាក់ |

## គ.២ ផែនការកែលំអរដែននេសាទ

**ផែនការកែលម្អរដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាង ខាងក្រោម ៖**

| ឈ្មោះ/ទីតាំង | ទំហំ | ទំហំដែលត្រូវកែលម្អរ | សកម្មភាព | ថ្ងៃ/ខែ / ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| បឹងក្បាលខ្សៀរ | ៥,៦ ហិចតា | តំណាក់កាលទី១<br>៨០មx១០០មx១,៥ម | • ស្វែងរកអ្នកជួយឧបត្ថម្ភ<br>• ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់<br>• សិក្សាលើទំហំដែលត្រូវស្តារ<br>• ចាប់ផ្តើមអនុវត្តស្តារ ៨០មx១០០មx១,៥ម | ២០១៨<br>មីនា | ២០២០<br>ឧសភា |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

**ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងក្បាលខ្សៀរ | ៥,៦ ហិចតា | រក្សាមេពូជត្រី | • ផ្សព្វផ្សាយពីកន្លែងអភិរក្ស<br>• ស្វែងរកម្ចាស់ជំនួយ<br>• បោះបង្គោលព្រំចំនួន៦ដើម<br>• ដាក់ស្លាកសញ្ញាចំនួន៦ស្លាក<br>• ដាក់ជម្រកសិប្បនិម្មិត<br>• ចុះល្បាតជាប្រចាំ<br>• ធ្វើស្នាក់ការល្បាត អំពីឈើប្រក់ ស័ង្កសី ៥ម គុណ ៣ម | ២០០០<br><br>១៦០០<br>៦០០<br>៥០០<br>៤៣២០<br>១៥០០ | ២០១៨ | ២០២០ |

### គ.៤ ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ដាំព្រៃនៅជុំវិញកន្លែងអភិរក្ស ចំនួន ៣៣០០០ដើម | ១០ ហិចតា | រាំង,ត្រស់,ចង្កេង បបួយ ផ្ដោល | • ប្រជុំផ្សព្វផ្សាយ<br>• ស្វែងរកអ្នកឧបត្ថម្ភ<br>• ដាំកូនឈើ<br>• បោះបង្គោលព្រំ ១០<br>• ស្លាកសញ្ញាចំនួន៤ | ៣០០<br><br>១២៣៧៥<br>១២០០<br>៦០០ | ២០១៨ | ២០២០ |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| វារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទពូជត្រី | បរិមាណកូនត្រីពូជ (ក្បាល) | ខែ / ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងបែរ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>• រៀបចំបែរ<br>• ផ្តល់កូនត្រី<br>• ថែរក្សា<br>• តាមដានត្រួតពិនិត្យ | បែរ ២០<br>៥ម×៣ម×២ម | ត្រី ប្រា<br>ត្រីអណ្តែង | ២០០០ក-៣០០០ក្ប/បែ | ០១/១៨<br>០១/១៩<br>០១/២០ | ១២/១៨<br>១២/១៩<br>១២/២០ |

### គ.៦- ផែនការចុះទប់ស្កាត់បទល្មើសនេសាទ

ផែនការចុះទប់ស្កាត់បទល្មើសនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ចំណាយដុល្លា | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| • អញ្ជើញអាជ្ញាធរពាក់ព័ន្ធចូលរួមប្រជុំ ១ដង/ឆ្នាំដើម្បីជួយគាំទ្រដល់ការអនុវត្តការងាររបស់សហគមន៍នេសាទ<br>• ប្រជុំផ្សព្វផ្សាយស្តីពីច្បាប់ជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ និងការប្រើប្រាស់ឧបករណ៍នេសាទ | • សហគមន៍នេសាទកាន់តែមានភាពរឹងមាំ និងមានការគាំទ្រច្រើន<br>• ប្រជាជនមានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ<br>• ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ៨០០ដុល្លា | អង្គការដៃគូ អាជ្ញាធរឃុំ | ២០១៨ | ២០២០ |
| • រៀបចំកំលាំងចុះបង្ក្រាបបទល្មើសនេសាទដោយមានកិច្ចសហការជាមួយមន្ត្រីជំនាញអាជ្ញាធរមូលដ្ឋាននិងអង្គភាពពាក់ព័ន្ធ | • បទល្មើសនេសាទថយចុះនិងឈានទៅលុបបំបាត់ទាំងស្រុង<br>• ធនធានជលផលកើនឡើង<br>• ជីវភាពសមាជិកសហគមន៍ធូរធារ | ៤៥០០ដុល្លា | អង្គការដៃគូ សហគមន៍ អាជ្ញាធរមូលដ្ឋាន | ២០១៨ | ២០២០ |

| | | | | | |
|---|---|---|---|---|---|
| • ទិញអាវភ្លៀង អាវពោង ពិល មួក កាត ទូរស័ព្ទ វិទ្យុទាក់ទង កែវយិត | • ចុះល្បាតដោយមានប្រសិទ្ធិភាព | ១៥០០ដុល្លា | អង្គការដៃគូ | ២០១៨ | ២០២០ |
| • ទិញទូកម៉ាស៊ីនចំនួន១គ្រឿង | • មានមធ្យោបាយសម្រាប់បំពេញការងារ | ១២០០ដុល្លា | អង្គការដៃគូ | ២០១៨ | ២០២០ |

## គ.៧- ផែនការបណ្តុះបណ្តាល

ផែនការបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ចំណាយដុល្លា | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| • រៀបចំសិក្ខាសាលាពីរបៀបសរសេររបាយការណ៍ កំណត់ហេតុ ជំនាញសម្របសម្រួលដោះស្រាយទំនាស់ក្នុងសហគមន៍ និងគម្រោងស្នើសុំថវិកា | -គណៈកម្មការ និងសមាជិកសហគមន៍នេសាទមានការយល់ដឹងអំពីផ្នែករដ្ឋបាលនិងការគ្រប់គ្រងចាត់ចែងថវិកាក្នុងការអនុវត្តជាក់ស្តែង<br>-កាត់បន្ថយទំនាស់ក្នុងសហគមន៍ | ៣៦០០ដុល្លា | ស្ថាប័នជំនាញ គណៈកម្មការ សមាជិកសហគមន៍នេសាទ | ម្តង/ឆ្នាំ ២០១៨ | ម្តង/ឆ្នាំ ២០២០ |

## គ.៨- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ១០០០៛/ម្នាក់ | ខែមករា/ ២០១៨ | ខែធ្នូ/២០២០ | ៤៣០.០០០៛ | |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ ២០០០៛/ម្នាក់ | ឆ្នាំ២០១៨ | ឆ្នាំ២០២០ | ២.៥៨០.០០០៛ | រយៈពេល ៣ឆ្នាំ |
| ប្រាក់ចំណូលពីអ្នកនេសាទក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍ បង់ភាគទានអាជីវកម្មនេសាទ | -ផ្សព្វផ្សាយជូនដំណឹងនេសាទក្នុងតំបន់មិនមែនសមាជិកសហគមន៍ បង់ប្រាក់ភាគទានអាជីវកម្មនេសាទ<br>-ប្រមូលភាគទានអាជីវកម្មនេសាទ ៤០០០៛/ម្នាក់ | មករា/២០១៨ | ធ្នូ/២០២០ | | រយៈពេល ៣ឆ្នាំ |
| ប្រាក់ចំណូលពីអ្នកនេសាទមកពីខាងក្រៅបង់ភាគទានអាជីវកម្មនេសាទ | ផ្សព្វផ្សាយជូនដំណឹងនេសាទមកពីខាងក្រៅបង់ភាគទាណអាជីវកម្មនេសាទ<br>-ប្រមូលភាគទានអាជីវកម្មនេសាទ ១០០០០៛/ម្នាក់ | មករា/២០១៨ | ធ្នូ/២០២០ | | រយៈពេល ៣ឆ្នាំ |

## ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានៈ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល និងខណ្ឌរដ្ឋជលផល អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងអង្គការនានាដើម្បីជួយផ្តល់យោបល់ចំពោះផែនការផ្សេងៗ ទាក់ទងនឹងបច្ចេកទេស ការរៀបចំកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងព្រៃលិចទឹក ការស្តារបឹង ព្រែក ស្រះ ការប្រើប្រាស់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់សហគមន៍ជាដើម។ល។

- រៀបចំផែនការ សម្រាប់ទំនាក់ទំនងស្វែងរកចំណូល តាមរយៈសមាជិកសហគមន៍ អ្នកនេសាទមកពីខាងក្រៅនិងតាមរយៈសប្បុរសជន៍ អង្គការនានា ផែនការវិនិយោគឃុំ ព្រមទាំងម្ចាស់ជំនួយផ្សេងៗ ដើម្បីគាំទ្រសហគមន៍។

- លើកផែនការ និងតម្រូវការរបស់សហគមន៍ បញ្ចូលជាមួយផែនការវិនិយោគឃុំ ប្រចាំឆ្នាំ ដោយជាក់លាក់ដែលមានការចូលរួមពីសមាជិកសហគមន៍។

- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។

- គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ ជាពិសេសក្រុមយុវវ័យ និងរៀបចំវិធានការចំពោះអ្នកមិនមែនជាសមាជិកសហគមន៍ និងអ្នកនេសាទមកពីខាងក្រៅ។

- ពង្រឹងសមត្ថភាព បច្ចេកទេស និងការគ្រប់គ្រងភាពជាអ្នកដឹកនាំ ព្រមទាំងសិទ្ធិតួនាទី ដល់គណៈកម្មការក្រុមល្បាត និងសមាជិកសហគមន៍នេសាទ។

- បង្កើតឲ្យមានគោលការណ៍ ប្រើប្រាស់ថវិកា ក្នុងការចំណាយចំណូលនៅក្នុងសហគមន៍ដែលមានការកំណត់សិទ្ធិ នៃការចំណាយទម្រង់ការប្រើប្រាស់ថវិកាដើម្បីឲ្យមានតម្លាភាព ។

- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ប្រឡាយមាសរយៈពេល ៣ ឆ្នាំ (២០១៨-២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | • ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | • សំបុរត្រីឡើងវិញ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | ២០០ដុល្លា | អង្គការដៃគូ | ដើមខែ០៦ រៀងរាល់ឆ្នាំ | ដើមខែ០៦ រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ |
| | • ត្រួតពិនិត្យនិងតាមដានលើការប្រើប្រាស់ឧបករណ៍នេសាទ | • សហគមន៍និងអ្នកនេសាទទាំងអស់អនុវត្តន៍តាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ | | | | | |
| ២.ផែនការកែលម្អដែននេសាទបឹងក្បាលខ្សៀរ | • ស្វែងរកអ្នកជួយឧបត្ថម្ភ<br>• ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់<br>• ធ្វើការសិក្សាលើទំហំដែលត្រូវស្តារ<br>• ចាប់ផ្តើមអនុវត្តស្តារ ទំហំ ៨០មX១០០មX១,៥ម=១២០០០ម³ | • ដែននេសាទនឹងត្រូវបានកែលម្អពីភាពរីងស្ងួតទៅជាកន្លែងដែលមានទឹកគ្រប់គ្រាន់គ្រប់រដូវ<br>• បង្កើនធនធានជលផលទាំងវារីសត្វ និងវារីរុក្ខជាតិ | ១៨.០០០ ដុល្លា (១ម³=១,៥$) ១ម៉ោង=៧៥$ | អង្គការដៃគូ | ០៤/២០១៨<br>០៤/២០១៩<br>០៤/២០២០ | ០៤/២០១៨<br>០៤/២០១៩<br>០៤/២០២០ | |
| ៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សបឹងក្បាលខ្សៀរ | • ស្វែងរកម្ចាស់ជំនួយ<br>• បោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស<br>• ដាក់ស្លាកសញ្ញា<br>• ដាក់ជម្រកត្រីសិប្បនិម្មិត<br>•សាងសង់ស្នាក់ការល្បាត<br>• ល្បាតប្រចាំការនៅកន្លែងអភិរក្ស | • ប្រភេទត្រីពូជសំខាន់ៗត្រូវបានអភិរក្ស<br>• ប្រជាជនបានយល់ដឹងនិងចូលរួមថែរក្សាកន្លែងអភិរក្ស<br>• កន្លែងអភិរក្សត្រូវបានរៀបចំឡើងនិងមានព្រំប្រទល់ច្បាស់លាស់<br>• បទល្មើនេសាទត្រូវបានកាត់បន្ថយ | ១០.៥២០ ដុល្លា | អង្គការដៃគូ | ២០១៨ | ២០២០ | |
| ៤.ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹកនៅជុំវិញកន្លែងអភិរក្ស ១០ហិចតា | • ប្រជុំផ្សព្វផ្សាយ<br>• ស្វែងរកអ្នកជួយឧបត្ថម្ភ | • ព្រៃលិចទឹកដែលបាត់បង់ត្រូវមានឡើងវិញ<br>• ប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់ព្រៃលិចទឹក<br>• បង្កើន វារីសត្វ រុក្ខជាតិ គ្រប់ប្រភេទ<br>• មានជម្រកសម្រាប់ត្រីពងកូន<br>• ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ | ៣០០ដុល្លា | -អង្គការដៃគូ<br>-សហគមន៍ | ខែ០១/ ២០១៨ | ខែ០១/ ២០១៨ | |
| | • ដាំកូនឈើចំនួន ៣៣០០០ដើម | | ១២៣៧៥ ដុល្លា | | ខែ០៦/ ២០១៨ | ខែ០៦/ ២០១៨ | |
| | • បោះបង្គោលព្រំប្រទល់ព្រៃលិចទឹកចំនួន១០បង្គោល | | ១២០០ដុល្លា | | ខែ០១/ ២០១៨ | ខែ០១/ ២០១៨ | |
| | • ដាក់ស្លាកសញ្ញាចំនួន៨ស្លាក | | ៦០០ដុល្លា | | ខែ០១/ | ខែ០១/ | |

| | | | | | | |
|---|---|---|---|---|---|---|
| | ១ស្លាក=១៥០ដុល្លា | | | | ២០១៨ | ២០១៨ | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្រ<br>• វគ្គបណ្ដុះបណ្ដាលបច្ចេទេសចិញ្ចឹមត្រី<br>• រៀបចំស្រះ ឬ បែរ<br>• ផ្ដល់កូនត្រី<br>• ផ្ដល់ចំណី<br>• ថែរក្សា<br>• តាមដានត្រួតពិនិត្យ<br>• ជ្រើសរើសពេលវេលាសមស្របក្នុងការប្រមូលផល | • សមាជិកគ្រួសារមួយចំនួនត្រូវបានជ្រើសរើសសម្រាប់ចិញ្ចឹមត្រីក្នុងស្រះនិងក្នុងបែ<br>• កូនត្រីប្រានិងត្រីអណ្ដែងចំនួន៥០០០០កូន នឹងត្រូវផ្ដល់អោយចំនួន២០គ្រួសារ<br>• រកប្រាក់ចំណូលជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយការធ្វើនេសាទត្រីពីធម្មជាតិ | ២៥០០ដុល្លា | សហគមន៍<br>ជលផល<br>អង្គការដៃគូ | ២០១៨ | ២០២០ | |
| ៦.ផែនការទប់ស្កាត់បទល្មើសនេសាទ | • អញ្ជើញអាជ្ញាធរពាក់ព័ន្ធចូលរួមប្រជុំ១ដង/ឆ្នាំដើម្បីជួយគាំទ្រដល់ការអនុវត្តការងាររបស់សហគមន៍នេសាទ<br>• ប្រជុំផ្សព្វផ្សាយស្ដីពីច្បាប់ជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ និងការប្រើប្រាស់ឧបករណ៍នេសាទ | • សហគមន៍នេសាទកាន់តែមានភាពរឹងមាំ និងមានការគាំទ្រច្រើន<br>• ប្រជាជនមានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ<br>• ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ៨០០ដុល្លា | អង្គការដៃគូ<br>អាជ្ញាធរឃុំ | | | |
| | • រៀបចំកំលាំងចុះបង្ក្រាបបទល្មើសនេសាទដោយមានកិច្ចសហការជាមួយមន្ត្រីជំនាញអាជ្ញាធរមូលដ្ឋាននិងអង្គភាពពាក់ព័ន្ធ | • បទល្មើសនេសាទថយចុះនិងឈានទៅលុបបំបាត់ទាំងស្រុង<br>• ធនធានជលផលកើនឡើង<br>• ជីវភាពសមាជិកសហគមន៍ធូរធារ | ៤៥០០ដុល្លា | អង្គការដៃគូ<br>សហគមន៍<br>អាជ្ញាធរមូលដ្ឋាន | ២០១៨ | ២០២០ | |
| | • ទិញអាវភ្លៀង អាវពោង ពិល មូក កាតទូរស័ព្ទ វិទ្យុទាក់ទង កែវយិត | • ចុះល្បាតដោយមានប្រសិទ្ធិភាព | ១៥០០ដុល្លា | អង្គការដៃគូ | ២០១៨ | ២០២០ | |
| | • ទិញទូកម៉ាស៊ីនចំនួន១គ្រឿង | • មានមធ្យោបាយសម្រាប់បំពេញការងារ | ១២០០ដុល្លា | អង្គការដៃគូ | ២០១៨ | ២០២០ | |
| ៧.ផែនការបណ្ដុះបណ្ដាល | • រៀបចំសិក្ខាសាលាពីរបៀបសរសេររបាយការណ៍ កំណត់ហេតុ ជំនាញសម្របសម្រួលដោះស្រាយទំនាស់សហគមន៍ និង គម្រោងស្នើសុំថវិកា | • គណៈកម្មការ សមាជិកសហគន៍យល់ដឹងអំពីផ្នែករដ្ឋបាល និងការគ្រប់គ្រងចាត់ចែងថវិកាក្នុងការអនុវត្តជាក់ស្ដែង<br>• កាត់បន្ថយទំនាស់ក្នុងសហគមន៍ | ៣៦០០ដុល្លា | អង្គការដៃគូ<br>ជំនាញជលផល | ២០១៨ | ២០២០ | |
| ៨.ផែនការថវិកាទ្រទ្រង់ | • ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ | • ថវិកាដែលបានមកពីសមាជិក | ១០៧.៥ដុល្លា | សមាជិក | ខែមករា/ | ខែធ្នូ/២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **សម្រាប់អភិវឌ្ឍន៍សហគមន៍** | ប្រាក់សមាជិកភាព<br>• ប្រមូលភាគទានសមាជិកសហគមន៍នេសាទ១០០០៛/ម្នាក់ | អ្នកមិនមែនជាសមាជិកសហគមន៍ អ្នកមកពីខាងក្រៅនិងជំនួយមកពីរាជរដ្ឋាភិបាល អង្គការដៃគូនានា នឹងត្រូវបានប្រើប្រាស់សម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ | | សហគមន៍ | ២០១៨ | | |
| | • ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ ២០០០៛/ម្នាក់ | | ៦៨៥ដុល្លា | សមាជិកសហគមន៍ | ២០១៨ | ២០២០ | |
| | • ប្រមូលថវិកាក្នុងតំបន់មិនមែនជាសមាជិកសហគមន៍នេសាទ ៤.០០០៛/ម្នាក់ | | | ប្រជាពលរដ្ឋក្នុងភូមិមិនមែនជាសមាជិកសហគមន៍ | ២០១៨ | ២០២០ | |
| | • ប្រមូលថវិកាមកពីខាងក្រៅសហគមន៍ ១០.០០០៛/ម្នាក់ | | | ប្រជាពលរដ្ឋមកពីក្រៅភូមិ | ២០១៨ | ២០២០ | |

## តារាងកម្មវិធីការងារផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ប្រឡាយមាស ឆ្នាំ (២០១៨-២០២០)

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | ២០២០ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ...... | ធ្នូ | មករា | ..... | ធ្នូ |
| **១.ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | |
| ១.១ ផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | √ | | | | | | | | √ | | | √ | |
| ១.២ ត្រួតពិនិត្យ តាមដានការប្រើប្រាស់ឧបករណ៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **២.ផែនការកែលម្អដែននេសាទ** | | | | | | | | | | | | | | | | | | |
| ២.១ ស្វែងរកអ្នកជួយឧបត្ថម្ភ | √ | | | | | | | | | | | | √ | | | √ | | |
| ២.២ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ | | √ | | | | | | | | | | | | √ | | √ | | |
| ២.៣ ធ្វើការសិក្សាលើទីតាំងនិងទំហំដែលត្រូវស្តារ | | √ | | | | | | | | | | | | √ | | | √ | |
| ២.៤ ចាប់ផ្តើមអនុវត្តការស្តារបឹង | | | √ | √ | | | | | | | | | | √ | | | √ | |
| **៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | |
| ៣.១ ស្វែងរកអ្នកជួយឧបត្ថម្ភ | √ | √ | | | | | | | | | | | | | | | | |
| ៣.២ បោះបង្គោលព្រំប្រទល់ | | | | | √ | √ | | | | | | | | | | | | |
| ៣.៣ ដាក់ស្លាកសញ្ញា | | | | | √ | √ | | | | | | | | | | | | |
| ៣.៤ ដាក់ជម្រកត្រីសិប្បនិម្មិត | | | | √ | √ | | | | | | | | | | | | | |
| ៣.៥ សាងសង់ស្នាក់ការល្បាត | | | √ | √ | √ | √ | √ | √ | | | | | | √ | | | √ | |
| ៣.៦ ល្បាតប្រចាំការនៅកន្លែងអភិរក្ស | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **៤.ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹក** | | | | | | | | | | | | | | | | | | |
| ៤.១ ប្រជុំផ្សព្វផ្សាយ | √ | | | | | | | | | | | | √ | | | √ | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.២ ស្វែងរកអ្នកជួយឧបត្ថម្ភ | √ | | | | | | | | | | | | √ | | | √ | | |
| ៤.៣ ដាំកូនឈើ | | | | | | √ | | | | | | | | √ | | | √ | |
| ៤.៤ បោះបង្គោលព្រំប្រទល់ព្រៃលិចទឹក | √ | | | | | | | | | | | | √ | | | √ | | |
| ៤.៥ ដាក់ស្លាកសញ្ញា | √ | | | | | | | | | | | | √ | | | √ | | |
| **៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | |
| ៥.១ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | √ | | | | | | | | | | | | √ | | | √ | | |
| ៥.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | | √ | | | | | | | | | | | | √ | | | √ | |
| ៥.៣ រៀបចំស្រះ ឬបែ | | | √ | | | | | | | | | | | √ | | | √ | |
| ៥.៤ ផ្តល់កូនត្រី | | | | √ | | | | | | | | | | √ | | | √ | |
| ៥.៥ ផ្តល់ចំណី | | | | √ | √ | √ | √ | √ | √ | √ | √ | | | √ | | √ | | |
| ៥.៦ ថែរក្សានិងព្យាបាល | | | | √ | √ | √ | √ | √ | √ | √ | √ | | | √ | | | √ | |
| ៥.៧ តាមដានត្រួតពិនិត្យ | | | | √ | √ | √ | √ | √ | √ | √ | √ | | | √ | | | √ | |
| ៥.៨ ជ្រើសរើសពេលវេលាសមស្របដើម្បីប្រមូលផល | | | | | | | | | √ | √ | √ | | | | | | | |
| **៦.ផែនការទប់ស្កាត់បទល្មើសនេសាទ** | | | | | | | | | | | | | | | | | | |
| ៦.១ អញ្ជើញអាជ្ញាធរចូលរួមប្រជុំ | | | | | √ | | | | | | | | | √ | | | √ | |
| ៦.២ ផ្សព្វផ្សាយច្បាប់ស្តីពីជលផល | | | | | √ | | | | | | | | | √ | | | √ | |
| ៦.៣ រៀបចំកំលាំងចុះបង្ក្រាបបទល្មើសនេសាទ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៦.៤ ទិញអាវពោង ពិល មួក វិទ្យុទាក់ទង កែវយឹត | | | √ | | | | | | | | | | | √ | | | √ | |
| ៦.៥ ទិញទូកម៉ាស៊ីន | | √ | √ | √ | √ | | | | | | | | | √ | | | √ | |
| **៧.ផែនការបណ្តុះបណ្តាល** | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.១ របៀបសរសេររបាយការណ៍ | √ | √ | √ | | | | | | | | | | √ | √ | | √ | √ | |
| ៧.២ របៀបសរសេរកំណត់ហេតុ | √ | √ | √ | | | | | | | | | | √ | √ | | √ | √ | |
| ៧.៣ ជំនាញសម្របសម្រួល | √ | √ | √ | | | | | | | | | | √ | √ | | √ | √ | |
| ៧.៤ របៀបដោះស្រាយទំនាស់ក្នុងសហគមន៍ | √ | √ | √ | | | | | | | | | | √ | √ | | √ | √ | |
| ៧.៤ របៀបសរសេរគម្រោងស្នើសុំថវិកា | | √ | | | | | | | | | | | | √ | | | √ | |
| **៨.ផែនការថវិកាទ្រទ្រង់ការអភិវឌ្ឍន៍ស.ន** | | | | | | | | | | | | | | | | | | |
| ៨.១ ផ្សព្វផ្សាយជ្រើសរើសសមាជិកសហគមន៍ | √ | | | | | | | | | | | | √ | | | √ | | |
| ៨.២ ប្រមូលប្រាក់ភាគទានសមាជិកសហគមន៍ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.៣ ប្រមូលប្រាក់ភាគទានប្រចាំឆ្នាំពីសមាជិក ស.ន | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.៤ ប្រមូលថវិកាពីអ្នកនៅក្នុងតបន់តែមិនមែនជាសមាជិក | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.៥ ប្រមូលថវិកាពីអ្នកមកពីខាងក្រៅសហគមន៍ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

សូមគោរពជូន

លោកមេឃុំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ ៩ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២

ប្រឡាយមាស ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ប្រឡាយមាស**

ភឹម_កុយ

លេខ ............

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

កំពង់ឆ្នាំង ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង**

សោម_តិរុណា

លេខ 123

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលកំពង់លែង

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ ៩ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២

ប្រឡាយមាស ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

**មេឃុំប្រឡាយមាស**

គង់_គន

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលផ្សារឆ្នាំង

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ ៩ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២

កំពង់លែង ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

**នាយសង្កាត់រដ្ឋបាលជលផលកំពង់លែង**

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ ៩ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ផ្សារឆ្នាំង ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

**នាយផ្នែករដ្ឋបាលជលផលផ្សារឆ្នាំង**

គង់សីហេង

លេខ ............

បានឃើញនិងគោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

កំពង់ឆ្នាំង ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៨

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង**

ខិន ហ៊ុន

លេខ ............

បានឃើញនិងឯកភាព

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន